# ផែនការយុទ្ធសាស្ត្ររបស់
# សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
# ២០១៤-២០១៨

*រួមគ្នាឆ្ពោះទៅរកឧត្តមភាព*

*ក្នុងការបណ្តុះបណ្តាល និងការស្រាវជ្រាវក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាល*

## ១. ចក្ខុវិស័យ

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នឹងក្លាយជាថ្នាលបណ្តុះបណ្តាលនាំមុខគេក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាល ដែលទទួលបាននូវការទទួលស្គាល់ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ហើយជាមជ្ឈដ្ឋានមួយ ដែលគ្រូ និស្សិត មន្ត្រី និង បុគ្គលិក សុទ្ធតែខិតខំនាំមកនូវឧត្តមភាព ក្នុងការ បង្រៀន ការសិក្សា ការស្រាវជ្រាវ និងការផ្តល់សេវាសាធារណៈ។

## ២. បេសកកម្ម

ស.វ.សនឹងរួមវិភាគទានធ្វើអោយសុខភាពប្រជាជនកម្ពុជា មានសុខភាពល្អប្រសើរឡើងតាមរយៈ៖

១. ការចូលរួមអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការបណ្តុះបណ្តាលទៅតាម និយាមជាតិ និងអន្តរជាតិ។

២. ការធ្វើការស្រាវជ្រាវដែលឆ្លើយតបទៅនឹងតំរូវការប្រទេសជាតិ ស្របតាម និយាមជាតិ និងអន្តរជាតិ។

៣. ការផ្តល់សេវាប្រកបដោយគុណភាព និងក្រមសីលធម៌ ។

៤. ការគ្រប់គ្រងអោយមានប្រសិទ្ធភាព និងតម្លាភាព។

៥. ការលើកកំពស់កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

## ៣. គោលការណ៍ជាមគ្គុទេសក៍

១. គ្រប់ពេលវេលាតែងតែខិតខំអនុវត្តភារកិច្ចឲ្យអស់ពីសមត្ថភាព

២. ផ្តល់តំលៃលើការសិក្សាបន្ត ឧត្តមភាព និង គុណភាព

៣. ប្រតិបត្តិការងារប្រកបដោយគណនេយ្យភាព តម្លាភាព និង វិជ្ជាជីវៈ

៤. ប្រតិបត្តិការងារប្រកបដោយភាពទទួលខុសត្រូវតាមឋានៈ និង ភារកិច្ច

៥. គោរពគ្នាទៅវិញទៅមកតាមឋានានុក្រម និង ភាពថ្លៃថ្នូរ

៦. លើកកំពស់គំនិតច្នៃប្រឌិត
៧. លើកកំពស់ស្មារតីការងារជាក្រុម
៨. លើកកំពស់គោលការណ៍លើកទឹកចិត្តតាមលទ្ធផលការងារ
៩. លើកកំពស់ភាពជាដៃគូ

## ៤. គោលដៅយុទ្ធសាស្ត្រ

- **គោលដៅចំបងទី ១៖** សំរេចបាននូវការទទួលស្គាល់ទាំងឧត្តមភាពការសិក្សា និងការអភិវឌ្ឍន៍និស្សិត និងគ្រូ។
- **គោលដៅចំបងទី ២៖** ត្រូវបានទទួលស្គាល់ជាសាកលវិទ្យាល័យនាំមុខគេមួយក្នុងការស្រាវជ្រាវ និង របកគំហើញវិទ្យាសាស្ត្រសុខាភិបាលថ្មីៗ នៅព្រះរាជាណាចក្រកម្ពុជា។
- **គោលដៅចំបងទី ៣៖** ចូលរួមចំណែកដល់ការផ្តល់សេវាឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍។
- **គោលដៅចំបងទី ៤៖** ធ្វើទំនើបកម្ម ព្រមទាំងលើកកំពស់អភិបាលកិច្ចល្អ។
- **គោលដៅចំបងទី ៥៖** មានធនធានសមស្របទាំងមនុស្ស ថវិកា និងហេដ្ឋារចនាសម្ព័ន្ធ សំរាប់ធ្វើការអភិវឌ្ឍ ទៅរកឧត្តមភាព។
- **គោលដៅចំបងទី ៦៖** ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ។